## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## សាលក្រមព្រហ្មទណ្ឌ

-លេខ ៦៣ "ព" ក្រ៧
ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ១៩៥១
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ១៤២៤
ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ៣៤៤៧
ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការសាធារណៈ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង៣០នាទី នៅសាលសវនាការទី៧ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកចៅក្រម ជាចៅក្រមប្រឹក្សា
-លោកចៅក្រម ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៥១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted]រ៉ាយុទ្ធ ហៅ ឆៃ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបររើសអេតចាយ ឪពុកឈ្មោះ [redacted] ឆាន់ "រស់" ម្ដាយឈ្មោះ [redacted]ផល "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)
ទីកន្លែងកំណើត: [redacted]ខេត្តព្រៃវែង។
អាសយដ្ឋានបច្ចុប្បន្ន: ផ្ទះជួល ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
ឃាត់ខ្លួនថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣។
ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៨៩៦ "ខ" ជ.ឃ.ជ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣។ (ម១)
ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២. ឈ្មោះ [redacted] ស្រីឡា ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ឪពុកឈ្មោះ [redacted] មាស "ស្លាប់" ម្ដាយឈ្មោះ [redacted]ខាន់ "រស់" ប្ដីឈ្មោះ ធី (លែងលះ) មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)
ទីកន្លែងកំណើត: [redacted] រាជធានីភ្នំពេញ។
អាសយដ្ឋានបច្ចុប្បន្ន: ផ្ទះជួល ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
ឃាត់ខ្លួនថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣។
ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៨៩៥ "ខ" ជ.ឃ.ជ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣។ (PJ)
ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ៣១ឆ្នាំ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៦ ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមស្រស់ ភេទស្រី អាយុ២១ឆ្នាំ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះជួល ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង០២ និង០០នាទី រំលងអធ្រាត្រ នៅត្រង់ចំណុចផ្ទះជួល ផ្លូវបេតុង ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ ជនជាប់ចោទឈ្មោះ [redacted] ស្រីឡា និងឈ្មោះ ខន ភេទប្រុស អាយុ៤១ឆ្នាំ។ នៅមុនពេលកើតហេតុ ជនរងគ្រោះឈ្មោះ [redacted] គឹមស្រស់ បានទុកម៉ូតូ០១គ្រឿងម៉ាក ហុងដាឌ្រីម C125 ពណ៌ខ្មៅ ឆ្នាំ២០១៥ ពាក់ផ្លាកលេខ 1FI-9495 ចំណែកជនរងគ្រោះឈ្មោះ [redacted] វិចិត្រ បានទុកម៉ូតូ០១គ្រឿង ម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ឆ្នាំ២០២២ ពាក់ផ្លាកលេខ 1JI-9440 ដោយបានចាក់សោក និងចាក់សោបិទទ្វារនៅច្រកចេញចូលខាងមុខផ្ទះជួលបានត្រឹមត្រូវ រួចជនរងគ្រោះទាំងពីរនាក់ នាំគ្នាឡើងទៅសម្រាកក្នុងបន្ទប់ជួលរៀងៗខ្លួន។ លុះដល់វេលាម៉ោង ០២ និង៣០នាទី រំលងអធ្រាត្រ ស្រាប់តែមានអ្នកស្នាក់នៅផ្ទះជួលបាននាំគ្នាឆោឡោថា បាត់ម៉ូតូ០២គ្រឿង ហើយទ្វារនៅខាងមុខផ្ទះបើកចំហ និងមានស្នាមគាស់មេសោដែលចាក់ជាប់នឹងទ្វាររបងខាងមុខផ្ទះជួលដាច់បាត់អស់។ លុះដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង៣០នាទី ទើបជនរងគ្រោះឈ្មោះ [redacted] គឹមស្រស់ និងឈ្មោះ [redacted] វិចិត្រ បាននាំគ្នាទៅរាយការណ៍ និងដាក់ពាក្យបណ្តឹងនៅទីស្នាក់ការប៉ុស្តិ៍នគរបាលរដ្ឋបាលកាកាបទី១ ដើម្បីឱ្យសមត្ថកិច្ចជួយអន្តរាគមន៍ស្រាវជ្រាវរកម៉ូតូ និងឃាត់ខ្លួនជនជាប់ចោទ។ រហូតមកដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង៣០នាទី សមត្ថកិច្ចបានស្រាវជ្រាវរកឃើញមុខសញ្ញា ហើយបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ និងឈ្មោះ [redacted] ស្រីឡា នៅចំណុចផ្លូវរថភ្លើង ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ចំណែកជនជាប់ចោទឈ្មោះ ខន ភេទប្រុស អាយុ៤១ឆ្នាំ រត់គេចខ្លួនបាត់។

-បានឃើញ របាយការណ៍សំយោគលេខ ០៧៧/២៣ រ.ប.ក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣១៩៥ អ.យ.ខ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២៩៤ "ង" ដ.ដ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ បានឆ្លើយថា កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង០០នាទីយប់ ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពចូលលួចម៉ូតូរបស់ជនរងគ្រោះជាមួយឈ្មោះ ខន ប្រាកដមែន នៅក្នុងពេលនោះឈ្មោះ ខន ជាអ្នកចូលឆ្កឹះសោម៉ូតូ ចំណែកខ្ញុំជាអ្នកចាំបណ្តើរម៉ូតូចេញ ហើយឈ្មោះ [redacted] ស្រីឡា ជាអ្នកមើលផ្លូវ។ ពួកខ្លួនលួចបានម៉ូតូ HONDA Dream C125 បានចំនួន០២គ្រឿង ខ្លួនជិះមួយគ្រឿង ចំណែកឈ្មោះ ខន ជិះមួយគ្រឿង យកមក



Scanned with CamScanner

បញ្ចាំងនៅឃ្លាំងវិសេវ បានប្រាក់ចំនួន ២.០០០.០០០(ពីរលាន)រៀល រួចហើយត្រឡប់មកផ្ទះវិញ។ ឈ្មោះ ខន បានឱ្យប្រាក់មកខ្លួនចំនួន ៥០០.០០០(ហាសិបម៉ឺន)រៀល និងឈ្មោះ [redacted] ស្រីឡា ចំនួន ៤០០.០០០(សែសិបម៉ឺន)រៀល។ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ចំណែកម៉ូតូសមត្ថកិច្ចប្រគល់ឱ្យម្ចាស់គេវិញហើយ។

ជនជាប់ចោទឈ្មោះ [redacted] ស្រីឡា បានឆ្លើយថា កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង០២ និង០០នាទីយប់ ខ្លួនបានជិះកង់ឌុបឈ្មោះ [redacted] រ៉ាយុទ្ធ មកដាក់នៅជិតផ្ទះជួលរបស់ជនរងគ្រោះ ហើយឈរចាំមើលផ្លូវ ដោយឈ្មោះ ខន និងឈ្មោះ [redacted] រ៉ាយុទ្ធ ជាអ្នកចូលទៅលួចយកម៉ូតូរបស់ជនរងគ្រោះនៅខាងក្នុងផ្ទះ។ ពួកខ្លួនលួចបានម៉ូតូចំនួន ០២ គ្រឿង ហើយឈ្មោះ ខន និងឈ្មោះ [redacted] រ៉ាយុទ្ធ ជាអ្នកយកទៅលក់។ ឈ្មោះ ខន បានឱ្យប្រាក់មកខ្លួនចំនួន ៤០០.០០០(សែសិបម៉ឺន)រៀល។ លុះដល់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ខ្លួនក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ហើយខ្លួនបាននាំសមត្ថកិច្ចទៅចាប់ខ្លួនឈ្មោះ [redacted] រ៉ាយុទ្ធ ម្នាក់ទៀត ចំណែកឈ្មោះ ខន បានរត់គេចខ្លួនបាត់។

ក្រឡាបញ្ជីអានកំណត់ហេតុបណ្តឹងឈ្មោះ [redacted] គីមស្រស់ បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ខ្លួនបានទុកម៉ូតូក្បែរបន្ទប់ទឹកក្នុងផ្ទះ ហើយខ្លួនបានទៅពេទ្យសម្រាកព្យាបាលជំងឺ លុះរហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ ខ្លួនក៏បានចេញពីពេទ្យត្រឡប់មកផ្ទះជួលវិញ ឃើញម៉ូតូនៅកន្លែងដដែលធម្មតា ឃើញដូចនេះខ្លួនក៏ឡើងទៅបន្ទប់សម្រាករហូតដល់ម៉ោងប្រហែល ០២ និង៣០នាទី ក៏ម្ចាស់ផ្ទះជួលខ្លួនគោះទ្វារហៅខ្លួនថា ម៉ូតូខ្លួនត្រូវបានចោរលួច ខ្លួនក៏ចុះមកមើលម៉ូតូទើបដឹងថា បាត់ត្រូវបានចោរលួចមែន។

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ២២ និង០០នាទី ខ្លួនបានយកម៉ូតូរបស់ខ្លួន ដែលមានម៉ាកដូចខាងលើទៅទុកផ្ទះជួលរបស់រូបខ្លួន ដែលបើកហាងថតចម្លងស្ថិតនៅក្នុងភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយមិនបានចាក់សោកម៉ូតូព្រមទាំងបិទសន្ទុះត្រឹមត្រូវនោះទេរួចក៏បានចេញទៅហូបអីខាងក្រៅបានមួយសន្ទុះរូបខ្លួនក៏បានត្រឡប់មកវិញរួចក៏បានឡើងទៅសម្រាកក្នុងបន្ទប់របស់ខ្លួនដែលនៅជាន់ឡៅតឿបាត់ទៅ លុះរហូតមកដល់វេលាម៉ោងប្រហែល ០០ និង៣០នាទី រំលងអធ្រាត្រ ឈានចូលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ រូបខ្លួនក៏បានចុះមករកមើលម៉ូតូ ស្រាប់តែបានបាត់ហើយសំលឹងមកមើលទ្វារផ្ទះខាងក្រោយឃើញបើកចំហរ ដោយដឹងដូចនោះខ្លួនក៏បានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលកាកាបទី១តែម្តង។ ខ្លួនបានទទួលម៉ូតូរបស់ខ្លួនមកវិញហើយ ហើយក៏មិនទាមទារអ្វីទៀតទេ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា តាមចម្លើយរបស់ជនជាប់ចោទទាំងពីរខាងលើ និងភស្តុតាងដែលសមត្ថកិច្ចបានដកហូត ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣១៩៥ អ.យ.ខ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា នៅចំពោះមុខអង្គសវនា កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពចំពោះអំពើរបស់ពួកគាត់ ម្យ៉ាងដោយសារកូនក្តីរបស់ខ្លួនមានកម្រិតចំណេះដឹងទាប



Scanned with CamScanner

និងមានជីវភាពក្រីក្រ ទើបកូនក្តីរបស់ខ្លួនសម្រេចចិត្តធ្វើអំពើបែបនេះ។ ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចដោយបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង។

កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ដោយសារនៅក្នុងរឿងនេះកូនក្តីរបស់ខ្លួនទាំងពីរនាក់បានឆ្លើយសារភាព ទទួលស្គាល់កំហុស ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចដោយបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆែ បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] ស្រីឡា បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា[1]

ក.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២៩៤ "ង" ង.ដ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៥១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆែ ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះ [redacted] ស្រីឡា ភេទស្រី អាយុ២៤ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។[2]

ខ.អង្គហេតុកើតឡើងនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។[3]

គ.អង្គហេតុកើតឡើងកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសទេ។[4]

ឃ.បើទោះបីជាដើមបណ្តឹងឈ្មោះ [redacted] គីមស្រស់ និងឈ្មោះ [redacted] វិចិត្រ មិនមានវត្តមាន នៅចំពោះមុខអង្គសវនាការក៏ដោយ ប៉ុន្តែតំណាងអយ្យការបានធ្វើការកោះហៅគ្រប់ភាគីពាក់ព័ន្ធឱ្យចូលរួមសវនាការ ជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង៣០នាទី ត្រឹមត្រូវរួចរាល់ហើយ ហេតុនេះតុលាការអាចបន្តសវនាការ ដោយកំបាំងមុខដើមបណ្តឹងបាន។

---

(1).មាត្រា៣៥០ មាត្រា៣៥១ និងមាត្រា៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(2).មាត្រា២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(3).មាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(4).មាត្រា១០ និង១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

ង.តាមរបាយការណ៍សំយោគលេខ ០៧៧/២៣ រ.ប.ក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ បានធ្វើការសន្និដ្ឋានថា ឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះ [redacted] ស្រីឡា ភេទស្រី អាយុ២៤ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ (យកដែកទួណឺវីសទៅគាស់មេសោចាក់ជាប់នឹងទ្វារផ្ទះជួល ចូលលួចយកម៉ូតូចំនួន០២គ្រឿង) កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង០០នាទីយប់រំលងអធ្រាត្រ នៅចំណុចផ្លូវបេតុង ផ្ទះជួល ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រាកដមែន។[5]

ច.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ បានឆ្លើយថា កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង០០នាទីយប់ ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពចូលលួចម៉ូតូរបស់ជនរងគ្រោះជាមួយឈ្មោះ ខន ប្រាកដមែន នៅក្នុងពេលនោះ ឈ្មោះ ខន ជាអ្នកចូលគ្រិះសោម៉ូតូ ចំណែកខ្ញុំជាអ្នកចាំបណ្តើរម៉ូតូចេញ ហើយឈ្មោះ [redacted] ស្រីឡា ជាអ្នកមើលផ្លូវ។ ពួកខ្លួនលួចបានម៉ូតូ HONDA Dream C125 បានចំនួន០២គ្រឿង ខ្លួនជិះមួយគ្រឿង ចំណែកឈ្មោះ ខន ជិះមួយគ្រឿង យកមកបញ្ចាំងនៅឃ្លាំងវំសេវ បានប្រាក់ចំនួន ២.០០០.០០០(ពីរលាន)រៀល រួចហើយត្រឡប់មកផ្ទះវិញ។ ឈ្មោះ ខន បានឱ្យប្រាក់មកខ្លួនចំនួន ៥០០.០០០(ហាសិបម៉ឺន)រៀល និងឈ្មោះ [redacted] ស្រីឡា ចំនួន ៤០០.០០០(សែសិបម៉ឺន)រៀល។ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ចំណែកម៉ូតូសមត្ថកិច្ចប្រគល់ឱ្យម្ចាស់គេវិញហើយ។

ឆ.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីឡា បានឆ្លើយថា កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង០០នាទីយប់ ខ្លួនបានជិះកង់ឌុបឈ្មោះ [redacted] រ៉ាយុទ្ធ មកដាក់នៅជិតផ្ទះជួលរបស់ជនរងគ្រោះ ហើយឈរចាំមើលផ្លូវដោយឈ្មោះ ខន និងឈ្មោះ [redacted] រ៉ាយុទ្ធ ជាអ្នកចូលទៅលួចយកម៉ូតូរបស់ជនរងគ្រោះនៅខាងក្នុងផ្ទះ។ ពួកខ្លួនលួចបានម៉ូតូចំនួន ០២ គ្រឿង ហើយឈ្មោះ ខន និងឈ្មោះ [redacted] រ៉ាយុទ្ធ ជាអ្នកយកទៅលក់។ ឈ្មោះ ខន បានឱ្យប្រាក់មកខ្លួនចំនួន ៤០០.០០០(សែសិបម៉ឺន)រៀល។ លុះដល់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ខ្លួនក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ហើយខ្លួនបាននាំសមត្ថកិច្ចទៅចាប់ខ្លួនឈ្មោះ [redacted] រ៉ាយុទ្ធ ម្នាក់ទៀត ចំណែកឈ្មោះ ខន បានរត់គេចខ្លួនបាត់។

ជ.តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គីមស្រស់ បានឆ្លើយថា នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ខ្លួនបានទុកម៉ូតូក្បែរបន្ទប់ទឹកក្នុងផ្ទះ ហើយខ្លួនបានទៅពេទ្យសម្រាកព្យាបាលជំងឺ លុះរហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ ខ្លួនក៏បានចេញពីពេទ្យត្រឡប់មកផ្ទះជួលវិញ ឃើញម៉ូតូនៅកន្លែងដដែលធម្មតា ឃើញដូចនេះខ្លួនក៏ឡើងទៅបន្ទប់សម្រាករហូតដល់ម៉ោងប្រហែល ០២ និង៣០នាទី ក៏ម្ចាស់ផ្ទះជួលខ្លួនគោះទ្វារហៅខ្លួនថា ម៉ូតូខ្លួនត្រូវបានចោរលួច ខ្លួនក៏ចុះមកមើលម៉ូតូទើបដឹងថា បាត់ត្រូវបានចោរលួចមែន។

ឈ.តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ បានឆ្លើយថា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ២២ និង០០នាទី ខ្លួនបានយកម៉ូតូរបស់ខ្លួន ដែលមានម៉ាកដូចខាងលើទៅទុកផ្ទះជួលរបស់រូបខ្លួន ដែលបើកហាងថតចម្លងស្ថិតនៅក្នុងភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយមិនបានចាក់សោកម៉ូតូព្រមទាំងបិទសន្ទះត្រឹមត្រូវនោះទេរួចក៏បានចេញទៅហូបអីខាងក្រៅបានមួយសន្ទុះរូបខ្លួនក៏បានត្រឡប់មកវិញរួចក៏បានឡើងទៅសម្រាកក្នុងបន្ទប់របស់ខ្លួនដែលនៅជាន់ខ្ពៅតឿបាត់ទៅ លុះរហូតមកដល់វេលាម៉ោងប្រហែល ០០ និង៣០នាទី រំលងអធ្រាត្រ ឈានចូលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ រូបខ្លួនក៏បានចុះមករកមើលម៉ូតូ ស្រាប់តែបានបាត់ហើយ

(5)(ឯកសារលេខ:៦) របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ។



Scanned with CamScanner

សំលឹងមកមើលទ្វារផ្ទះខាងក្រោយឃើញបើកចំហរ ដោយដឹងដូចនោះខ្លួនក៏បានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលកាកាបទី១តែម្តង។ ខ្លួនបានទទួលម៉ូតូរបស់ខ្លួនមកវិញហើយ ហើយក៏មិនទាមទារអ្វីទៀតទេ។

ញ.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ និងឈ្មោះ [redacted] ស្រីឡា ដែលបានធ្វើសកម្មភាពលួចយកម៉ូតូរបស់ជនរងគ្រោះ គឺជាចេតនាទុច្ចរិត ក្នុងបំណងដកហូតយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន។

ដ.តាមចម្លើយជនជាប់ចោទទាំង០២នាក់ខាងលើ ក៏ដូចជាអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងរបាយការណ៍សំយោគរបស់សមត្ថកិច្ច និងភស្តុតាងផ្សេងៗទៀត មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ និងឈ្មោះ [redacted] ស្រីឡា ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

ឋ.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ដែលបានធ្វើសកម្មភាពគាស់សោចូលលួចយកម៉ូតូរបស់ជនរងគ្រោះ ដោយមានជនជាប់ចោទឈ្មោះ [redacted] ស្រីឡា ជាអ្នកឈរចាំមើលផ្លូវ បើផ្អែកតាមធាតុនីត្យានុកូលស្របទៅនឹងបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សាដោយការកាច់គាស់ទម្លុះទម្លាយ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

-មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ ក្នុងករណី អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា។

ឌ.ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះ ម៉ាង ស្រីឡា ភេទស្រី អាយុ២៤ឆ្នាំ ជានីតិជន មានស្មារតីល្អ មានការយល់ដឹងខុសត្រូវច្បាស់លាស់ ហើយក៏ពុំមានសញ្ញាណណាមួយបញ្ជាក់ថាជននេះមានវិបល្លាសស្មារតីអ្វីដែរ។

ឍ.អំពើដែលជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ និងឈ្មោះ [redacted] ស្រីឡា បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ជាអំពើដែលច្បាប់ហាមឃាត់ និងតម្រូវឱ្យផ្តន្ទាទោស។

ណ.តាមកំណត់ហេតុបណ្តឹង ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ របស់ឈ្មោះ ហាន គឹមស្រស់ និងឈ្មោះ [redacted] វិចិត្រ មិនបានទាមទារសំណងពីជនជាប់ចោទនោះទេ ហើយដើមបណ្តឹងមិនបានបង្ហាញវត្តមាននៅចំពោះមុខអង្គសវនាការ ហេតុនេះតុលាមិនគប្បីលើកយកករណីសំណងរដ្ឋប្បវេណី មកធ្វើការពិចារណានោះទេ។

ត.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន នៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣១៩៥ អ.យ.ខ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ការស្នើសុំតុលាការនឹងលើកយកមកពិចារណា។

ថ.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចដោយបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន ការស្នើសុំតុលាការនឹងលើកយកមកពិចារណា។

ទ.ជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ និងជនជាប់ចោទឈ្មោះ [redacted] ស្រីឡា បានសំណូមពរសូមឱ្យលោកចៅក្រមមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។



Scanned with CamScanner

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះ [redacted] ស្រីឡា ភេទស្រី អាយុ២៤ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ ភេទប្រុស អាយុ៣៨ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៤(បួន)ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ស្រីឡា ភេទស្រី អាយុ២៤ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី) ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។[6]

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង១៤ និង៣០នាទីរសៀល ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រ៉ាយុទ្ធ ហៅ ឆៃ និងឈ្មោះ [redacted] ស្រីឡា និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង០៩ និង ០០នាទី។[7]

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់។[8]

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| លោក [redacted] | | | |

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

(6).មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(7).មាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(8).មាត្រា[illegible], មាត្រា[illegible] និងមាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner